**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-១៩១ គ.ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** ការស្នើសុំប្តូរនិមិត្តសញ្ញា (Logo) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។
**យោង ៖** លិខិតលេខ ៩៧៥ សហវ អឧហ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនលោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឲ្យបានជ្រាបថា កន្លងមក ការប្រើប្រាស់និមិត្តសញ្ញារបស់គ្រឹះស្ថានមួយចំនួន មានលក្ខណៈស្រដៀងគ្នាជាមួយនិមិត្តសញ្ញារបស់ក្រសួង-ស្ថាប័នរដ្ឋ ដែលកំពុងប្រើប្រាស់ ដូចជា អក្សរ "រ" ឬ "រូបសិង្ហ" ជាដើម ដែលនាំឲ្យមានការភាន់ច្រឡំជាច្រើនពីសំណាក់សាធារណជនថា គ្រឹះស្ថាននោះ គឺជាគ្រឹះស្ថានរបស់រដ្ឋ ។ តាមរយៈការចុះដល់មូលដ្ឋាន ប្រជាពលរដ្ឋភាគច្រើនយល់ថា មន្ត្រី-បុគ្គលិករបស់គ្រឹះស្ថាន គឺជាមន្ត្រី-បុគ្គលិករដ្ឋ ។ ការភាន់ច្រឡំនេះអាចជះឥទ្ធិពលមិនល្អចំពោះគ្រឹះស្ថាន ដោយសារសាធារណជន ជាពិសេសអ្នកទទួលបានឥណទានពីគ្រឹះស្ថានយល់ថា បើគាត់មិនទូទាត់សងត្រឡប់ ក៏មិនមានបញ្ហាអ្វីដែរ ព្រោះជាគ្រឹះស្ថានរបស់រដ្ឋ ដែលអាចបណ្តាលឲ្យគ្រឹះស្ថានរងនូវការខាតបង់ ឬ បណ្តាលឲ្យមានហានិភ័យជាប្រព័ន្ធដល់គ្រឹះស្ថានផ្សេងៗទៀត ។

ដើម្បីចៀសវាងនូវបញ្ហានេះ ធនាគារជាតិនៃកម្ពុជាសូមស្នើដល់លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ប្តូរនិមិត្តសញ្ញា ដែលមានលក្ខណៈស្រដៀងគ្នាជាមួយនឹងនិមិត្តសញ្ញារបស់ក្រសួង-ស្ថាប័នរដ្ឋ និងគួរចៀសវាងការប្រើប្រាស់និមិត្តសញ្ញាណាដែលអាចធ្វើឲ្យសាធារណជនយល់ច្រឡំថា ជាគ្រឹះស្ថានរបស់រដ្ឋ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ជ្រាប និងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ត.ប ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណោរ៉ះ**